## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខៈ ១០៧៧ សជណ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខៈ ២៩០១ ប្រក ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល នៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២២ សមាគមមានសមាជិកសរុបចំនួន ៣១៦ស្ថានីយ / ក្រុមហ៊ុន ដែលបាន នឹងកំពុងប្រតិបត្តិការនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកជាប្រតិបត្តិករផ្គត់ផ្គត់ទឹកស្អាតចំនួន ២៨២ស្ថានីយ និងសមាជិកជាក្រុមហ៊ុនផ្គត់ផ្គង់លើវិស័យទឹកស្អាតចំនួន ៣៤ក្រុមហ៊ុន។

## ២. ក្រុមប្រឹក្សាភិបាល

### ២.១ កិច្ចប្រជុំកក្រុមប្រឹក្សាភិបាល

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២២ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក) បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសម្រាប់ត្រីមាសទី២ ក្នុងគោលបំណង៖

- អនុម័តទៅលើកំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រីមាសទី១ ឆ្នាំ២០២២
- ការធ្វើបទបង្ហាញពីកំណត់ហេតុប្រជុំនៅត្រីមាសទី១ (ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២)
- របាយការណ៍រីកចម្រើនប្រចាំត្រីមាសទី២ និងផែនការសកម្មភាពសម្រាប់ត្រីមាសទី៣
- របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ និងផែនការហិរញ្ញវត្ថុសម្រាប់ត្រីមាសទី៣

### ២.២ កិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាល

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាល បានរៀបចំកិច្ចប្រជុំវិសាមមញ្ញតាមប្រព័ន្ធអនឡាញ (ZOOM-Call) និងបានសម្រេចដូចខាងក្រោម៖

១. ក្រុមប្រឹក្សាភិបាលសមាគម និងនាយកប្រតិបត្តិ នឹងរកពេលវេលាសមគួរដើម្បីចូលជួបសម្តែងការគួរសម និងគោរពជូនពរ ថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងឱកាស បុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ។

២. កិច្ចប្រជុំបានសម្រេចរៀបចំសន្និសីទ និងការតាំងពិព័រណ៌ទឹក នៅចុងខែវិច្ឆិកា ឆ្នាំ២០២២

៣. សមាគម និងជ្រើសរើសទីប្រឹក្សាម្នាក់ដើម្បីជួយសមាគមក្នុងការកែលម្អផែនការយុទ្ធសាស្ត្រ និងជដែកជាមួយដៃគូរផ្សេងៗ។

- ប្រធានក្រុមប្រឹក្សាភិបាល លោក ឡេង ខៀវ ស្នើឱ្យមានការផ្សព្វផ្សាយពីការប្រើប្រាស់ទឹកស្អាត។

### ២.៣ ការជួបសំណេះសំណាល

ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ លោក ឡេង ខៀវ ប្រធានក្រុមប្រឹក្សាភិបាល បានដឹកនាំក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិសមាគម ចូលជួបសម្តែងការគួរសម និងគោរពជូនពរ ឯកឧត្តម គតិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ។ សូម ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី លោកជំទាវ និងបុត្រា បុត្រី ព្រមទាំងចៅៗជាទីស្រឡាញ់ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទាំងអស់ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ សូមទទួលបានសុខភាពល្អបរិបូរណ៍ ពលានុភាពខ្លាំងក្លាប្រាជ្ញាវាងវៃ ជោគជ័យគ្រប់ភារកិច្ច និងសមប្រកបតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ឆ្លៀតក្នុងឱកាសនោះដែរ ក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិសមាគម ក៏បានចូលជួបដើម្បីសម្តែងការគួរសម និងគោរពជូនពរក្នុងឱកាសបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរជូនដល់ ឯកឧត្តម អ៊ុំ សុថា រដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងឯកឧត្តម តន់ សុខជា អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ផងដែរ។



*រូបភាពទី ១ ការថតរូបអនុស្សាវរីយ៍ក្នុងឱកាសជួបសម្តែងការគួរសម និងគោរពជូនពរថ្នាក់ដឹកនាំក្រសួងឧ.រ.ប.ន*

## ៣. ការខារស្លួលសមាគម

### ៣.១ វគ្គបណ្តុះបណ្តាល

នៅក្នុងត្រីមាសទី៣ សមាគមបានសហការជាមួយមន្ទីរឧ.រ.ប.ន និងសាខាពន្ធដារខេត្ត ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«កាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» បានចំនួន ២វគ្គ។ វគ្គបណ្តុះបណ្តាលមានគោលបំណងឱ្យអ្នកចូលរួមអាចៈ

- រៀបរាប់បានពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ
- រៀបរាប់បានពីនីតិវិធីក្នុងការចុះបញ្ជីពន្ធដារនិងរបៀបនៃការបង់ពន្ធសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ សមាគមបានសហការជាមួយ មន្ទីរឧ.រ.ប.ន ខេត្តតាកែវ និង សាខាពន្ធដារ ខេត្តតាកែវ រៀបចំវគ្គបណ្តុះបណ្តាលស្តីពី«កាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» នៅសណ្ឋាគារអាលីសរីឡា ខេត្តតាកែវ។

វគ្គបណ្តុះបណ្តាលនេះមានការអញ្ជើញចូលរួមជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ពី លោក កេត ព្រុង ប្រធានមន្ទីរ ឧ.រ.ប.ន ខេត្តតាកែវ និង លោក ជិន គឹមស្រេង ប្រធានសាខាពន្ធដារ ខេត្តតាកែវ និងមានអ្នកចូលរួមសរុបចំនួន ៣៨នាក់ (ស្រី ១៣នាក់) ដែលអញ្ជើញពី មន្ទីរសាខាពន្ធដារ ខេត្តតាកែវ មន្ទីរឧ.រ.ប.ន ខេត្តតាកែវ តំណាងម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត និងបុគ្គលិកសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។



*រូបភាពទី ២ វគ្គបណ្តុះបណ្តាលស្តីពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធ(តាកែវ)*

ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ សមាគមបានសហការជាមួយ មន្ទីរឧ.រ.ប.ន ខេត្តកំពង់ស្ពឺ និងសាខាពន្ធដារ ខេត្តកំពង់ស្ពឺ រៀបចំវគ្គបណ្តុះបណ្តាលស្តីពី«កាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» នៅសាលប្រជុំមន្ទីរឧ.រ.ប.ន ខេត្តកំពង់ស្ពឺ។

វគ្គបណ្តុះបណ្តាលនេះមានការអញ្ជើញចូលរួមជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ពី លោក នួន សុភ័ណ្ឌ ប្រធានមន្ទីរ ឧ.រ.ប.ន ខេត្តកំពង់ស្ពឺ និង លោក ងួន ពៅពេជ្រ អនុប្រធានសាខាពន្ធដារ ខេត្តកំពង់ស្ពឺ និងមានអ្នកចូលរួមសរុប ៣៧នាក់ (ស្ត្រី ៤នាក់) វគ្គបណ្តុះបណ្តាលមាន ការអញ្ជើញចូលរួមពីប្រតិបត្តិករនៅក្នុងខេត្តកំពង់ស្ពឺ មន្ទីរឧ.រ.ប.ន ខេត្តកំពង់ស្ពឺ សាខាពន្ធដារ ខេត្តកំពង់ស្ពឺ និងបុគ្គលិកសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។



*រូបភាពទី ៣ វគ្គបណ្តុះបណ្តាលស្តីពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធ(កំពង់ស្ពឺ)*

## ៣.២ កិច្ចប្រជុំតាមតំបន់

ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ នៅសណ្ឋាគារ ហាន គង់ ដោយមានការចូលរួមសហការឧបត្ថម្ភពីក្រុមហ៊ុន ធីស៊ីយូ(TCU) ក្រុមហ៊ុន ភ្នំពេញប្លាស្ទិច ប្រូដាក់ (Phnom Penh Plastic Product) ក្រុមហ៊ុន អេចធីអេហ្វ (HTS) ក្រុមហ៊ុន ធីអ៊ីអឹម(TEM) និងក្រុមហ៊ុនដៃគូទឹកកម្ពុជា (Water Partner) ដែលមានអ្នកចូលរួមសរុប ៥៣នាក់ (ស្រី ១០នាក់) ក្នុងនោះមាន ២៦ស្ថានីយ និង ៥ក្រុមហ៊ុន។



*រូបភាពទី ៤ ការថតរូបអនុស្សាវរីយ៍ក្នុងកិច្ចប្រជុំតាមតំបន់នៅខេត្តសៀមរាប*

## ៣.៣ ភាពជាអ្នកតំណាងសមាជិក

- ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ សមាគមបានប្រគល់ប្រាក់ ចំនួន ៤៤២៤.៥៣ដុល្លារ (បួនពាន់បួនរយម្ភៃបួនដុល្លា និងហាសិបបីសេន) ដែលជាការបរិច្ចាគរបស់សមាជិកសមាគមជូន មូលនិធិគន្ធបុប្ផាកម្ពុជា តាមរយៈក្រសួងឧ.វ.ប.ន។



*រូបភាពទី ៥ កាប្រគល់ប្រាក់រៃអង្គាសសម្រាប់មូលនិធិគន្ធបុប្ផាកម្ពុជាតាមរយៈអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧ.វ.ប.ន*

❖ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ លោក ឡេង ខៀវ ប្រធានក្រុមប្រឹក្សាភិបាលសមាគមបានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ ជាមួយ លោក ឈឹម វាសនា តំណាងឱ្យ លោក ផាន់ ម៉ារី ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតទន្លេបិទ ដើម្បីស្វែងរកដំណោះស្រាយចំពោះការមិនចាត់វិធានការតាមផ្លូវច្បាប់ក្នុងផ្អាកការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹក ដែលគ្មានប្រកាសអនុញ្ញាតត្រឹមត្រូវនៅភូមិសាស្ត្រឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ (ដែលស្ថិតនៅក្នុងប្រកាសអនុញ្ញាតរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតទន្លេបិទ) តាមលិខិតលេខៈ ២៣៤៦ ឧរបន.ទស ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១។



*រូបភាពទី ៦ កិច្ចប្រជុំជាមួយក្រុមប្រឹក្សាភិបាល សមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតទន្លេបិទ*

❖ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ សមាគមបានរៀបចំកិច្ចប្រជុំជាមួយ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតមកពីខេត្តកំពង់ឆ្នាំង ដែលជាសមាជិករបស់សមាគម ដើម្បីពិភាក្សារកដំណោះស្រាយអំពី ការធ្វើផ្លូវលំនៅក្នុងខេត្តកំពង់ឆ្នាំង បានធ្វើឱ្យខូចខាត់បំពង់ទឹកស្អាតរបស់ប្រតិបត្តិករ។ កិច្ចប្រជុំនេះមានការចូលរពី លោក ឡេង ខៀវ ប្រធានក្រុមប្រឹក្សាភិបាល សមាជិកក្រុមប្រឹក្សា បុគ្គលិកសមាគម និងតំណាងប្រតិបត្តិករចំនួន ១០នាក់ មកពី ៧ស្ថានីយ។ ក្រោយពីការពិភាក្សាយ៉ាងផុលផុសមក អង្គប្រជុំសម្រេចថា នឹងរៀបចំកិច្ចប្រជុំនៅសាលាស្រុកកំពង់ត្រឡាច ដោយអញ្ជើញសមាសភាពចូលរួមមានៈ តំណាងអភិបាលខេត្ត និងសាលាខេត្តកំពង់ឆ្នាំង មន្ទីរឧ.វ.ប.ន មន្ទីរអភិវឌ្ឍន៍ជនបទ អភិបាលស្រុកទាំងអស់ក្នុងខេត្ត មេឃុំនៅក្នុងឃុំគោលដៅនិងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតទាំងអស់ក្នុងខេត្ត។



*រូបភាពទី ៧ កិច្ចប្រជុំជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត មកពីខេត្តកំពង់ឆ្នាំង*

# ៤. ការងារគម្រោង

## ៤.១ ការបង្កើននូវភាពធន់នឹងការបម្រែបម្រួលអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (UNICEF)

### ៤.១.១ ការចុះបង្វឹក

- ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ បុគ្គលិកបច្ចេកទេស សមាគមបានចុះទៅបង្វឹកផ្ទាល់ដល់បុគ្គលិកស្ថានីយផ្គត់ផ្គង់ទឹកស្អាត ប៉េង ហុង ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សេក គង់ បាត់ដឹង និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតបូរីជល់សារ ស្តីពី«ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុដើម្បីប្រព័ន្ធប្រព្រឹត្តិកម្មទឹកស្អាត» ក្រោមជំនួយឧបត្ថម្ភពីអង្គការ UNICEF។



*រូបភាពទី ៨ ការចុះទៅបង្វឹកផ្ទាល់ដល់បុគ្គលិកបច្ចេកទេសស្ថានីយផ្គត់ផ្គង់ទឹកស្អាត*

### ៤.១.២ វគ្គបណ្តុះបណ្តាល

- ថ្ងៃទី០៩-១១ ខែសីហា ឆ្នាំ២០២២ សមាគម បានសហការជាមួយ ក្រសួង ឧ.វ.ប.ន រៀបចំវគ្គបណ្តុះបណ្តាល និងពិគ្រោះយោបល់អំពីគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ក្រោមជំនួយឧបត្ថម្ភរបស់អង្គការ (UNICEF) នៅភោជនីយដ្ឋានទន្លេបាសាក់២ ក្រោមអធិបតីភាព ឯកឧត្តម រស់ សាលីន អនុរដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពស់ខ្ពស់របស់ ឯកឧត្តមកិតិសេដ្ឋា ទេសរដ្ឋមន្រ្តី រដ្ឋមន្រ្តី ក្រសួង ឧ.វ.ប.ន។



*រូបភាពទី ៩ ការគោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា មុនពេលបើកវគ្គ*

វគ្គបណ្តុះបណ្តាលមានអ្នកចូលរួមសរុប ៨៥នាក់ ដែលអញ្ជើញមកពី មន្ទីរឧ.វ.ប.ន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនមកពីខេត្តកំពង់ស្ពឺ និងខេត្តតាកែវ តំណាងអង្គការ យូនីសេហ្វ និងបុគ្គលិកសមាគម។



*រូបភាពទី ១០ ការធ្វើបទបង្ហាញរបស់ បណ្ឌិត សេង ប៊ុនរិទ្ធ*

### ៤.១.៣ ការផ្ទៀងផ្ទាត់ទៅលើការដំឡើង និងផ្គត់ផ្គង់ប្រព័ន្ធថាមពលសូឡា

❖ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ បុគ្គលិកបច្ចេកទេសសមាគម បានចុះពិនិត្យមើលការដំឡើង និងផ្គត់ផ្គង់ប្រព័ន្ធថាមពលសូឡា នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត សេក គង់ បាត់ដឹង និងស្ថានីយ ផ្គត់ផ្គង់ទឹកស្អាត ប៉េង ហុង ក្រោមជំនួយពីអង្គកា UNICEF តាមរយៈគម្រោង«បង្កើននូវភាពធន និង អាកាសធាតុសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត ដល់ប្រជាជនរស់នៅក្នុងឃុំដែលមានហានិភ័យទៅនឹងអាកាសធាតុ»។



*រូបភាពទី ១១ ការដំឡើងប្រព័ន្ធថាមពល សូឡានៅស្ថានីយទឹកស្អាត សេក គង់ បាត់ដឹង*

## ៤.២ ការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សន្តិសុខទឹក នៅកម្រិតស្រុកក្នុងប្រទេសកម្ពុជា-WaterAid

### ៤.២.១ កិច្ចប្រជុំផ្សព្វផ្សាយតាមខ្នងផ្ទះអំពី«សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត»

- ថ្ងៃទី១៥-១៦ ខែកញ្ញា ឆ្នាំ២០២២ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានបើកវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយតាមខ្នងផ្ទះអំពី«សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត» ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដែលមានអ្នកចូលរួមសរុបចំនួន ១៨នាក់ (ស្រី ៨នាក់) នៅសាលាស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។




*រូបភាពទី ១២ បើកវគ្គបណ្តុះបណ្តាល នៅសាលាស្រុកសាមគ្គីមានជ័យ*

### ៤.២.២ រៀបចំកិច្ចប្រជុំផ្សព្វផ្សាយតាមសហគមន៍«សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត»

- ថ្ងៃទី២៥ -២៦ ខែសីហា ឆ្នាំ២០២២ សមាគម បានការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយតាមសហគមន៍ស្តីពី «សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត» ជូនប្រជាពលរដ្ឋ។ អ្នកចូលរួមសរុបចំនួន ៩១នាក់ (ស្រី ៦៦នាក់) នៅក្នុងឃុំចំនួន ៣ ក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ព្រមទាំងផ្តល់ឧបករណ៍តេស្តគុណភាពស្អាតជូនប្រតិបត្តិករចំនួន ៥ស្ថានីយ ដែលស្ថិតនៅក្នុងស្រុកសាមគ្គីមានជ័យ។



*រូបភាពទី ១៣ កិច្ចប្រជុំសហគមន៍ នៅឃុំពាម ស្រុកសាមគ្គីមានជ័យ (បទបង្ហាញដោយ កញ្ញា ខាត់ ដាវី)*

## ៤.៣ ការពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាត ដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត នៅក្នុងខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង (WaterAid)

### ៤.៣.១ វគ្គបង្វឹកស្ដីពី «ការតេស្តគុណភាពទឹកស្អាត»

សមាគមបានសហការជាមួយរដ្ឋបាលស្រុក និងមន្ទីរឧ.វ.ប.ន ខេត្តកំពង់ស្ពឺ និងខេត្តកណ្ដាល រៀបចំវគ្គបង្វឹកស្ដីពី «ការតេស្តគុណភាពទឹកស្អាត» ចំនួន ១៧ឃុំ ដូចខាងក្រោម៖

- ស្រុកអង្គស្នួល៖ ចំនួន ១០ឃុំ មានអ្នកចូលរួមសរុបចំនួន ៧៩នាក់ (ស្រី ១៩នាក់)
- ស្រុកកណ្ដាលស្ទឹង៖ ចំនួន ៣ឃុំ អ្នកចូលរួមសរុបចំនួន ២២នាក់ (ស្រី ៧នាក់)
- ស្រុកថ្ពង៖ ចំនួន ៤ឃុំ អ្នកចូលរួមសរុបចំនួន ៣២នាក់ (ស្រី ៨នាក់)។



*រូបភាពទី ១៤ វគ្គបង្ហឹកនៅឃុំប្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ*

### ៤.៣.២ កិច្ចប្រជុំថ្នាក់ឃុំ

សមាគមបានសហការជាមួយរដ្ឋបាលស្រុក និងមន្ទីរឧ.វ.ប.ន ខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល រៀបចំកិច្ចប្រជុំថ្នាក់ឃុំស្តីពី «សេវាផ្គត់ផ្គង់ទឹកស្អាត» បានចំនួន ១២ឃុំ ដូចខាងក្រោម៖

១. ស្រុកអង្គស្នួល៖ ចំនួន ១០ឃុំ មានអ្នកចូលរួមសរុបចំនួន ៣៤៨នាក់ (ស្រី ៧០នាក់)។

២. ស្រុកថ្ពង៖ ចំនួន ២ឃុំ អ្នកចូលរួមសរុបចំនួន ៤០នាក់ (ស្រី ១០នាក់)។




*រូបភាពទី ១៥, ១៦ &១៧ ការសម្របសម្រួលកិច្ចប្រជុំថ្នាក់ឃុំ*





### ៤.៣.៣ កិច្ចប្រជុំថ្នាក់ឃុំជាមួយអង្គការដៃគូ

នៅក្នុងត្រីមាសទី៣នេះ សមាគមបានចូលរួមកិច្ចប្រជុំដែលរៀបចំដោយ អង្គការ វ៉តជីអេត ចំនួន ៣ លើកដូចខាងក្រោយម៖

លើកទី១៖ កិច្ចប្រជុំឆ្លុះបញ្ចាំងកម្មវិធី នៅសាលាខេត្តកណ្ដាល

លើកទី២៖ សិក្ខាសាលាស្ដីពីការ គោលការណ៍ទឹកស្អាត និងអនាម័យសម្រាប់សម្រាប់ជនមានពិការភាពប្រកបដោយបរិយាបន្ន។

លើកទី៣៖ សិក្ខាសាលាឆ្លុះបញ្ចាំងអំពីភាពជាដៃគូ។



*រូបភាពទី ១៨ កិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោងរបស់អង្គការ វ៉តជីអេត*

### ៤.៣.៤ ជំនួយឧបត្ថម្ភធនលើតំណភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្រ

សមាគមបានសម្របសម្រួលភ្ជាប់សេវាទឹកស្អាតជូនគ្រួសារក្រីក្របានចំនួន ៣៨០គ្រួសារ៖

- ២៨៤ គ្រួសារបានផ្ទៀងផ្ទាត់រួច
- ៩៦ គ្រួសារមិនទាន់បានផ្ទៀងផ្ទាត់ (ក្រុមការងារនឹងផ្ទៀងផ្ទាត់នៅត្រីមាសក្រោយ)។







*រូបភាពទី ១៩ គ្រួសារក្រីក្រនៅឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង*

## ៤.៤ គម្រោងបង្កើនការទទួលសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុសម្រាប់ជនងាយរងគ្រោះនៅតាមសហគមន៍ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីឆ្នើមក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន ( WaterAid )

### ៤.៤.១ វគ្គបណ្តុះបណ្តាល

សមាគមបានសហការជាមួយ រដ្ឋបាលស្រុក និងមន្ទីរឧ.រ.ប.ន ខេត្តកណ្តាល រៀបចំវគ្គបណ្តុះបណ្តាលស្តីពី «តួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងសហគមន៍ចំពោះសេវាកម្មទឹកស្អាត» និង«បច្ចេកទេសនៃការផលិតទឹកស្អាត និងការតេស្តគុណភាពទឹកស្អាត» ព្រមទាំងផ្តល់ឧបករណ៍តេស្តគុណភាពទឹក និងវាស់សម្ពាធទឹកដល់អាជ្ញាធរស្រុកទាំងពីរ។ សមាសភាពចូលរួមពីតំណាង មន្ទីរឧ.រ.ប.ន និងតំណាង មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកណ្តាល តំណាងរដ្ឋបាលស្រុកល្វាឯម ក្រុមប្រឹក្សាឃុំ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត តំណាងអង្គការវ៉តជីអេតកម្ពុជា៖

- ❖ **ស្រុកស្អាង៖** មានអ្នកចូលរួមសរុបចំនួន ២៥នាក់ (ស្រី ៥នាក់)
- ❖ **ស្រុកល្វាឯម៖** មានអ្នកចូលរួមសរុបចំនួន ២០នាក់ (ស្រី ៨នាក់)




*រូបភាពទី ២០ ការបើកវគ្គបណ្តុះបណ្តាល ស្រុកល្វាឯម ខេត្តកណ្តាល*

សមាគមបានសហការជាមួយរដ្ឋបាលស្រុក និងមន្ទីរឧ.រ.ប.ន ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពី «វិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងទឹកជំនន់ សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត» មានសមាសភាពចូលរួមពីតំណាងមន្ទីរឧ.រ.ប.ន និងតំណាងមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកណ្តាល តំណាងរដ្ឋបាលស្រុកល្វាឯម ក្រុមប្រឹក្សាឃុំ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត៖

1. ស្រុកស្អាង៖ មានអ្នកចូលរួមសរុបចំនួន ១៧នាក់ (ស្រី ៣នាក់)
2. ស្រុកល្វាឯម៖ មានអ្នកចូលរួមសរុបចំនួន ១១នាក់ (ស្រី ២នាក់)



*រូបភាពទី ២១ កិច្ចពិភាក្សាក្រុមក្នុងវគ្គបណ្តុះបណ្តាល ស្រុកស្អាង ខេត្តកណ្តាល*

សមាគមបានសហការជាមួយរដ្ឋបាលស្រុក និងមន្ទីរឧ.រ.ប.ន ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយតាមខ្នងផ្ទះអំពី«សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត» មានសមាសភាពចូលរួមពីតំណាងរដ្ឋបាលស្រុកល្វាឯម ក្រុមប្រឹក្សាឃុំ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត៖

១. ស្រុកស្អាង៖ មានអ្នកចូលរួមសរុបចំនួន ២១នាក់ (ស្រី ៩នាក់)

២. ស្រុកល្វាឯម៖ មានអ្នកចូលរួមសរុបចំនួន ១៤នាក់ (ស្រី ៧នាក់)

សមាគមក៏បានចែកសម្ភារផ្សព្វផ្សាយជូនរដ្ឋបាលស្រុក ឃុំ និងប្រតិបត្តិករ



*រូបភាពទី ២២ វគ្គបណ្តុះបណ្តាល ស្រុកស្អាង ខេត្តកណ្តាល*

## ៤.៤២. ផ្ទៀងផ្ទាត់គ្រួសារក្រីក្រ

បុគ្គលិកសមាគមបានចុះទៅផ្ទៀងផ្ទាត់គ្រួសារក្រីក្រដែលបានភ្ជាប់ទឹកស្អាតរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ៣ស្ថានីយ ក្រោមបដិភាគរបស់ប្រតិបត្តិករ អង្គការវ៉តែជីអេត និងគ្រួសារក្រីក្រ។

- ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្រើយស្លា ចំនួន ១០៩គ្រួសារ ក្នុងឃុំប្រាសាទ
- ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកោះខ្សាច់ទន្លា ចំនួន ៤៥គ្រួសារ ក្នុងឃុំកោះខ្សាច់ទន្លា
- ស្ថានីយផ្គត់ផ្គង់ទឹកស្អាតស្វាយប្រទាល ចំនួន ៣១គ្រួសារ ក្នុងឃុំស្វាយប្រទាល





*រូបភាពទី ២៣ គ្រួសារក្រីក្របានភ្ជាប់ទឹកស្អាត ស្រុកស្អាង ខេត្តកណ្តាល*

## ៤.៥ គម្រោងឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកជូនគ្រួសារក្រីក្រ (EMW)

សូមអបអរសាទរ ចំពោះម្ចាស់ស្ថានីយ ជាស្ត្រីទាំងបីរូប ក្នុងការខិតខំតភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្រ តាមរយៈគម្រោង«ការតភ្ជាប់បណ្តាញទឹកស្អាតទៅលើការឧបត្ថម្ភធនគ្រួសារក្រីក្រសម្រាប់ប្រតិបត្តិករដែលដឹកនាំដោយស្ត្រី» ឧបត្ថម្ភដោយ អង្គការលោកខាងលិចជួបខាងកើត (EMW)



*រូបភាពទី ២៤ ការផ្តល់រង្វាន់ជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត*

## ៤.៦ គម្រោងសម្ព័ន្ធភាពដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌ ( Aide et Action )

### ៤.៦.១ សិក្សាសមិទ្ធិលទ្ធភាព និងសរសេររបាយការណ៍

នៅក្នុងត្រីមាសទី៣នេះ សមាគមបានរៀបចំការសិក្សាសមិទ្ធិលទ្ធភាព និងសរសេររបាយការណ៍បានចំនួន ៥ស្រុក៖

១. សម្រាប់ខេត្តកំពត បាន ចំនួន ២ ស្រុកគឺស្រុកទឹកឈូ និងស្រុកកំពង់ត្រាច ។

២. សម្រាប់ខេត្តកែប បានចំនួន ១ ស្រុក គឺស្រុកដំណាក់ចង្អើរ។

៣. សម្រាប់ខេត្តកោះកុង បានចំនួន ២ស្រុក គឺស្រុកគិរីសាគរ និងស្រុកបុទុមសាគរ



*រូបភាពទី ២៥ កិច្ចពិភាក្សាក្រុមរបស់សិក្ខាកាមនៅស្រុកស្រែអំបិល*

## ៤.៧ គម្រោងសិក្សារៀបចំព័ត៌មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត សម្រាប់គេហទំព័រ-Water.org

### ៤.៧.១ រៀបចំកិច្ចប្រជុំពីភាក្សាអំពីការប្រមូលទិន្នន័យ

សមាគមបានសម្របសម្រួលកិច្ចប្រជុំចំនួនពីរ (២)លើក ដើម្បីពិភាក្សាអំពីការប្រមូលទិន្នន័យសម្រាប់ «ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»៖

លើកទី១៖ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ មានប្រតិបត្តិករទឹកស្អាតចូលរួមសរុបចំនួន ១០ស្ថានីយ តាមកម្មវិធី Zoom អនឡាញ។

លើកទី២៖ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ មានប្រតិបត្តិករចូលរួមសរុបចំនួន ៧ស្ថានីយ នៅការិយាល័យសមាគម។



*រូបភាពទី ២៦ កិច្ចប្រជុំផ្សព្វផ្សាយគម្រោងដល់អាជីវករផ្គត់ផ្គត់ទឹកស្អាត នៅការិយាល័យសមាគម*